**ប្រការ ៣** : គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

១–ផ្តល់នូវទិសដៅ គោលនយោបាយសំរាប់ការអនុវត្តន៍គំរោងការ

២–តាមដាននូវការរីកចំរើនទៅមុខ និងផលប្រយោជន៍របស់គំរោងការ

៣–ជួយដោះស្រាយនូវបញ្ហានានា ដើម្បីធានានូវការអនុវត្តន៍គំរោងអោយបានឆាប់រហ័យ និង ប្រកបដោយប្រសិទ្ធភាព ។

៤–ទំនាក់ទំនងសហការអន្តរជាតិរវាងរាជាណាចក្រកម្ពុជាជាមួលសាធារណរដ្ឋសង្គមនិយមវៀតណាម

៥–ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលទាំងពីរ ស្តីពីការកែប្រែគំរោងប្លង់

**ប្រការ ៤** : គណៈកម្មការនេះត្រូវធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥** : បណ្តាស្ថាប័នពាក់ព័ន្ធ ឯកឧត្តមអស់លោកដូចមានឈ្មោះក្នុងគណៈកម្មការនេះត្រូវអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពល្អចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
ហត្ថលេខា និង ត្រា
**អ៊ឹង គៀត**

* * *

# ៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

# ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៩៧ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យចក—ដំរីលនៅជា**

**«អនុវិទ្យាល័យ ហេង សំរិន » ស្ថិតនៅក្នុងស្រុក ស្ទឹងត្រង់ ខេត្តកំពង់ចាម**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យចក–ជីរល ចុះថ្ងៃទី ០១ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតប្តូរឈ្មោះអនុវិទ្យាល័យចក–ជីរល ទៅជា «អនុវិទ្យាល័យ **ហេង សំរិន**» ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា –ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ចាម និង នាយកអនុវិទ្យាល័យ **ហេង សំរិន** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៩៨ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះវិទ្យាល័យខ្សាច់កណ្តាលទៅជា**